ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ១៤៨/២០

ការិយាល័យសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ចូល លេខ: 2301
ថ្ងៃ 07.10.20 ម៉ោង
បញ្ជូន............ម៉ោង

**សូមគោរពជូន**

**សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

**កម្មវត្ថុ៖** ជំនួបជាមួយប្រតិភូស្ថានទូតសហរដ្ឋអាមេរិក អំពីការវាយតម្លៃរបស់សហរដ្ឋអាមេរិក លើកិច្ចខិតខំប្រឹងប្រែងរបស់ព្រះរាជាណាចក្រកម្ពុជា លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពជម្រាបជូន **សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ចាប់តាំងពីគោរពទទួលបានអនុសាសន៍ដ៏ខ្ពង់ខ្ពស់**សម្ដេចក្រឡាហោម** ឲ្យមានជំនួបជាមួយស្ថានទូតសហរដ្ឋអាមេរិកពាក់ព័ន្ធនឹងចំណាត់ថ្នាក់រួចមក នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ នាងខ្ញុំបានរៀបចំឲ្យមានជំនួបរវាងអន្តរក្រសួង-ស្ថាប័ន ជាមួយគណៈប្រតិភូ សហរដ្ឋអាមេរិក នៅអាគារ ៩ ក្រសួងមហាផ្ទៃ ដែលដឹកនាំដោយ លោកជំទាវ **វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូត វិសាមញ្ញ និងពេញសមត្ថភាព សហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ។

នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ ក្រុមការងារបច្ចេកទេសពីស្ថានទូតសហរដ្ឋអាមេរិកចំនួន ០៤នាក់ ជាមន្ត្រីស្ថានទូត និង អង្គការ USAID ក៏បានមកជួបនាងខ្ញុំនៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

**ជាលទ្ធផល៖**

ស្ថានទូតសហរដ្ឋអាមេរិក ប្រាប់ថា ខ្លួនមានបំណងជួយស្ដារកិត្តិយសរាជរដ្ឋាភិបាលកម្ពុជា ក្នុងការជម្រុញចំណាត់ថ្នាក់ឲ្យចេញផុតពីលេខ២ ក្នុងបញ្ជីឃ្លាំមើល ព្រោះថា បើលទ្ធផលមិនមានអ្វីដែលប្រសើរទេ កម្ពុជានឹងទទួលបានលេខ៣ ដោយស្វ័យប្រវត្តិ ហើយត្រូវប្រឈមនឹងការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ។

ក្នុងន័យ អាមេរិក បានសង្កត់ធ្ងន់លើការខិតខំប្រឹងប្រែងលើសកម្មភាពគន្លឹះចំនួន ០៥ ក្នុងចំណោមអនុសាសន៍ទាំង ១៧ ដែលបានដាក់ចេញ ក្នុងនោះរួមមាន៖

១. លើកកម្ពស់ការប្រមូលទិន្នន័យអំពីការអនុវត្តច្បាប់ និងការផ្ដន្ទាទោស ដោយធ្វើការចែករំលែកព័ត៌មាន និងរបាយការណ៍ទាំងនោះ ទៅក្នុងចំណោមក្រសួងស្ថាប័នពាក់ព័ន្ធ

២. ខិតខំពង្រីកការអនុវត្តគោលការណ៍ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ឲ្យបានទូលំទូលាយ និងមានរបាយការណ៍ជាក់លាក់អំពីសេវាកម្មទាំងឡាយដែលបានផ្ដល់ដល់ជនរងគ្រោះ

៣. អនុញ្ញាតឲ្យមានការអនុវត្តបច្ចេកទេសស៊ើបអង្កេតសម្ងាត់ ដើម្បីស្វែងរកបទល្មើស និងជនល្មើស ដើម្បីបង្ក្រាបឲ្យមានប្រសិទ្ធភាព

៤. បង្កើនការធ្វើអធិការកិច្ច ដោយមិនបានផ្តល់ព័ត៌មានជាមុន ដល់ក្រុមហ៊ុនជ្រើសរើសពលករ សហគ្រាស ដែលសង្ស័យថាមានបង្កប់នូវសេវាកម្មពាក់ព័ន្ធនឹងការជួញដូរ និងកេងប្រវ័ញ្ច ជាពិសេសពលកម្មកុមារ

៥. បង្កើនការសិក្សាស្រាវជ្រាវលើស្ថាប័នប្រាក់កម្ចី ជាពិសេសអ្នកពាក់ព័ន្ធ(ថៅកែក្រុមហ៊ុន...) ដែលធ្វើឲ្យពលករជាប់អន្ទាក់ទាសភាពបំណុល ។

**ចំពោះដំណោះស្រាយៈ**

**អនុសាសន៍ទី១-** ក្រសួងយុត្តិធម៌ បានប្តេជ្ញាចិត្ត ធ្វើឲ្យប្រសើរឡើងនូវកិច្ចការប្រមូលទិន្នន័យ និងចែករំលែកនេះ ដោយដាក់រដ្ឋលេខាធិការមួយរូបឲ្យទទួលខុសត្រូវ ។

**អនុសាសន៍ទី២-** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាអ្នកទទួលខុសត្រូវក្នុងការពង្រឹកការបណ្តុះបណ្តាល និងតាមដានការអនុវត្ត និងធ្វើការកែលម្អរបាយការណ៍ ឲ្យមានភាពជាក់លាក់ជាងមុន ។

**អនុសាសន៍ទី៣-** ពាក់ព័ន្ធនឹងការស៊ើបអង្កេតសម្ងាត់ អគ្គស្នងការនគរបាលជាតិ បានត្រៀមប្រជុំពិភាក្សាជាមួយក្រសួងយុត្តិធម៌ និងអ្នកជំនាញសហរដ្ឋអាមេរិក ដើម្បីរកដំណោះស្រាយ ស្តីពីការអនុវត្តវិធានបច្ចេកទេសនៃការស៊ើបអង្កេតសម្ងាត់ ក្នុងកម្រិតណាមួយ ដែលមិនប៉ះពាល់នឹងការរំលោភសិទ្ធិបុគ្គល ដែលផ្ទុយនឹងច្បាប់ជាតិ ។

**អនុសាសន៍ទី៤-** អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងស្វែងរកកិច្ចសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គស្នងការដ្ឋាននគរបាលជាតិ និងស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងរបៀបរបបនៃការធ្វើអធិការកិច្ច ឲ្យមានលទ្ធផលល្អប្រសើរជាងមុន ដើម្បីកាត់បន្ថយភាពរងគ្រោះរបស់ពលករ និងកុមារ ។

**អនុសាសន៍ទី៥-** ក្រសួងមហាផ្ទៃ និងអាជ្ញាធរមូលដ្ឋាន បានយកចិត្តទុកដាក់តាមដានបញ្ហានេះ ហើយក៏បានធ្វើការស្រាវជ្រាវ អំពីបំណុល ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានដាក់ចេញនូវវិធានការ ជាបន្តបន្ទាប់អំពីគោលការណ៍នៃប្រាក់កម្ចី ដែលមានអត្រាការប្រាក់ទាប ។ តែទោះបីជាយ៉ាងនេះក្តីប្រាក់កម្ចីពីឯកជន មេខ្យល់ ក្រុមហ៊ុន និងនិយោជក គឺជារឿងសំខាន់ ដែលពលករត្រូវធ្វើការដោះបំណុលមិនចេះចប់ និងមានការកេងប្រវ័ញ្ចខ្ពស់ ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងរិះរកវិធានការបន្ថែមទៀត ដើម្បីដោះស្រាយបញ្ហានេះ ។

ចំពោះការប្រមូលទិន្នន័យ អង្គការ USAID បានស្នើសុំឲ្យមានកិច្ចសហការជាមួយមន្ត្រីជំនាញរបស់ខ្លួន ដើម្បីជួយដល់ការងារប្រមូលទិន្នន័យ ដោយធ្វើការជិតស្និទ្ធជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

រាជរដ្ឋាភិបាលកម្ពុជា សង្ឃឹមថា នឹងមានកិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើរ ជាមួយដៃគូជាតិ អន្តរជាតិ សង្គមស៊ីវិល ជាពិសេស ក្នុងវិស័យព័ត៌មាន ទិន្នន័យ និងការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស បានកាន់តែល្អប្រសើរសម្រាប់ឆ្នាំថ្មី ជាពិសេស ជាមួយអ្នកជំនាញសហរដ្ឋអាមេរិក ។

អាស្រ័យហេតុនេះ សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងគោរពសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់ ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ៕

ថ្ងៃចន្ទ ៣រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០២០

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**